ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ....១៧៩........ សខ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១១..

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
អគ្គលេខាធិការដ្ឋាន
ចូល
លេខ....២៣...........
ថ្ងៃទី០៣..០៣..១១ម៉ោង..........
បញ្ជូន..........................

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារដើម្បីកុមារ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ខែមករាឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.តត ចុះថ្ងៃទី ២២ ខែ កម្ភៈ ឆ្នាំ ២០១០ ស្តីពីការតែងតាំងសមាសភាព នៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ
- បានឃើញសេចក្តីសម្រេចលេខ ១២៧ កជក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០ របស់ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ ស្តីពីការបង្កើតក្រុមការងារដើម្បីកុមារ នៅតាមក្រសួង ស្ថាប័ន
- ពិនិត្យតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១.-** ត្រូវបានបង្កើត ក្រុមការងារដើម្បីកុមារ នៃក្រសួងសុខាភិបាល ដូចមានរាយនាមខាងក្រោមនេះ :

| | | | | |
|---|---|---|---|---|
| ១ | លោកជំទាវសាស្ត្រាចារ្យ | **តាន់ ទួចឆេង** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២ | លោកសាស្ត្រាចារ្យ | **សាន់ ច័ន្ទសឿន** | អគ្គនាយករងបច្ចេកទេសសុខាភិបាល | អនុប្រធាន |
| ៣ | លោកស្រីវេជ្ជបណ្ឌិត | **ប្រាក់ ពិសិដ្ឋរង្សី** | ប្រធាននាយកដ្ឋានការពារសុខភាព | សមាជិក |
| ៤ | លោកវេជ្ជបណ្ឌិត | **សុខ ស្រ៊ុន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | - |
| ៥ | លោកស្រីវេជ្ជបណ្ឌិត | **ទុង រដ្ឋាវី** | អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារ មាតា និងទារក | - |
| ៦ | លោកវេជ្ជបណ្ឌិត | **ប៊ុន ស្រេង** | ប្រធានការិ.ត្រួតពិនិត្យ និងបង្ការជម្ងឺឆ្លង នៃនាយកដ្ឋានប្រយុទ្ធនឹងជម្ងឺឆ្លង | - |
| ៧ | លោកវេជ្ជបណ្ឌិត | **អ៊ុំ កេតវណ្ណា** | ប្រធានកម្មវិធីជាតិអាហារូបត្ថម្ភ នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | - |




ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨២៦ ០៣៤/៨៨៤ ៩០៩ ទូរស័ព្ទ:(៨៥៥-២៣) ៧២២ ៩៣៣

**ប្រការ២.-** ក្រុមការងារដើម្បីកុមារ នៃក្រសួងសុខាភិបាល មានតួនាទី និងភារកិច្ច ដូចមានចែងក្នុងសេចក្ដីសម្រេច លេខ ១២៧ កជក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១០ របស់ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ ស្ដីពី ការបង្កើតក្រុមការងារដើម្បីកុមារ នៅតាមក្រសួង ស្ថាប័ន ។

**ប្រការ ៣.-** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល ប្រធានអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដែលមាននាមក្នុងប្រការ ១ ត្រូវទទួលភារៈអនុវត្តតាមសេចក្ដី សម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ម៉ម-ប៊ុនហេង**

**កន្លែងទទួល :**

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ ៗ